World Health Organization
Western Pacific Region

# កម្ពុជា

## របាយការណ៍ស្តីពីស្ថានភាពជំងឺកូវីដ-១៩ លេខ#៨៤

០៣ ឧសភា ឆ្នាំ២០២១

របាយការណ៍គិតត្រឹមថ្ងៃទី ០៣ ឧសភា ឆ្នាំ២០២១ ម៉ោង១០:០០នាទីព្រឹក

## ស្ថានការណ៍សង្ខេប

### សម្រង់សង្ខេបនៃរបាយការណ៍អំពីស្ថានភាពជំងឺកូវីដ-១៩ ពេលបច្ចុប្បន្ន

- នៅក្នុងរយៈពេល ៧ថ្ងៃចុងក្រោយ មានករណីវិជ្ជមានវីរុសកូវីដ-១៩ចំនួនសរុប ៤.៨០៦ករណី (៥ករណីនាំចូល និង ឆ្លងក្នុងស្រុក ៤.៨០១ករណី) និងករណីស្លាប់២៧ករណី ត្រូវបានរាយការណ៍។
- ចាប់តាំងពីការចាប់ផ្តើមនៃការផ្ទុះជំងឺនាពេលបច្ចុប្បន្ននេះ មានករណីជំងឺកូវីដ-១៩ឆ្លងនៅក្នុងប្រទេសចំនួន ១៤.៨០៨ករណី ត្រូវបានរាយការណ៍នៅក្នុងខេត្តចំនួន ២៣ រួមទាំងខេត្តស្ទឹងត្រែងមួយបន្ថែមទៀតនៅក្នុងសប្តាហ៍កន្លងមកនេះ។
- ខេត្តឧត្តរមានជ័យ បានរាយការណ៍ពីករណីវិជ្ជមានវីរុសកូវីដ-១៩នាំចូលលើកទី១ កាលពីថ្ងៃទី ៣០ ខែមេសា។
- គិតត្រឹមថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០២១ វេលាម៉ោង១០ ម៉ោងសកល មានអ្នកវិជ្ជមានវីរុសកូវីដ-១៩ ចំនួនសរុប ១៥.៣៦១ករណី ដែលត្រូវបានបញ្ជាក់ថាជាករណីជំងឺកូវីដ-១៩ និងករណីស្លាប់១០៦ករណី ត្រូវបានរាយការណ៍ដោយរដ្ឋាភិបាលកម្ពុជា។ ក្នុងចំណោមនោះមានចំនួន ៥.៤៣០ករណី បានជាសះស្បើយ។ អ្នកជំងឺកូវីដ-១៩ ចំនួន ៩.៨១៨នាក់ កំពុងសម្រាកព្យាបាលនៅមន្ទីរពេទ្យ។
- ចាប់តាំងពីខែមករា ឆ្នាំ២០២០ មក មានបុគ្គលចំនួន ៦៣៦.០៤២ ត្រូវបានធ្វើតេស្តរកវីរុសកូវីដ-១៩ ដោយប្រើបច្ចេកវិទ្យាធ្វើតេស្តបែប Real-Time Polymerase Chain Reaction (RT-PCR) ដោយមានអត្រាវិជ្ជមានក្នុងកម្រិត ២,៤ ភាគរយ។ ជាសរុប គិតត្រឹមថ្ងៃទី ០៣ ខែឧសភា មានចំនួនតេស្ត ៨៥៥.២១០ ត្រូវបានធ្វើ។

## ព្រឹត្តិការណ៍ដែលនឹងកើតមាន និងវិធានការអាទិភាព

**ការតាមដានជំងឺ**

- យុទ្ធសាស្ត្រតាមដានជំងឺ ត្រូវបានធ្វើបុច្ចុប្បន្នភាព និងធ្វើបទបង្ហាញទៅបណ្តាខេត្តនានា ដើម្បីគាំទ្រដល់បណ្តាខេត្តទាំងនោះនៅក្នុងការស្វែងរកជំងឺអោយបានឆាប់។
- ក្រសួងសុខាភិបាល ដោយមានការគាំទ្រពីអង្គការសុខភាពពិភពលោក កំពុងតែរៀបចំបង្កើតវិធីសាស្ត្រស្វែងរកអ្នកពាក់ព័ន្ធឲ្យទៅជាលក្ខណៈប្រព័ន្ធមួយ ដើម្បីពង្រីកទៅប្រើប្រាស់នៅតាមខេត្តទាំងអស់នៅទូទាំងប្រទេស។
- ក្រសួងសុខាភិបាល ដោយមានការគាំទ្រពីអង្គការសុខភាពពិភពលោក កំពុងធ្វើការវាយតម្លៃស្ថានភាព និងដំណាក់កាលនៃការចម្លងប្រចាំសប្តាហ៍ ដោយប្រើប្រព័ន្ធតាមដានជំងឺផ្អែកលើព័ត៌មានមកពីច្រើនប្រភព។
- ដោយមានការគាំទ្រពីអង្គការសុខភាពពិភពលោក ក្រសួងសុខាភិបាលនឹងពង្រឹងសមត្ថភាពរាជធានី ខេត្តសម្រាប់ការប្រើប្រាស់មជ្ឈមណ្ឌលប្រតិបត្តិការសង្គ្រោះបន្ទាន់ / ប្រព័ន្ធគ្រប់គ្រងករណីឆ្លងជំងឺ (EOC / IMS) និងការតាមដានប្រភពជាច្រើនសម្រាប់ការវាយតម្លៃហានិភ័យ និងការសម្រេចចិត្ត។

**មន្ទីរពិសោធន៍**

- អង្គការសុខភាពពិភពលោក និងវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា កំពុងជួយគាំទ្រក្រសួងសុខាភិបាលនៅក្នុងការបញ្ជាក់ថា ឧបករណ៍តេស្តផ្តល់លទ្ធផលរហ័សត្រឹមត្រូវ។
- អង្គការសុខភាពពិភពលោក កំពុងជួយគាំទ្រផ្នែកបច្ចេកទេសពីចម្ងាយ ដល់មជ្ឈមណ្ឌលជាតិផ្តល់ឈាម និងមន្ទីរពិសោធន៍ខេត្តព្រះសីហនុ។
- វិទ្យាស្ថានប៉ាស្ទ័រកម្ពុជាកំពុងធ្វើតេស្តនៅមន្ទីរពិសោធន៍ ការពនិត្យលំដាប់ហ្សែន និងការវិភាគសេរ៉ូមសាស្ត្រ។
- ក្រសួងសុខាភិបាល កំពុងតែធ្វើតេស្តមន្ទីរពិសោធន៍ និងការស្រាវជ្រាវរកប្រភពនៃការចម្លង។ ក្រសួងសុខាភិបាល ដោយមានការគាំទ្រពីដៃគូ បាននិងកំពុងតែធ្វើការប្រមូលសំណាក និងតេស្តបន្ថែមទៀត ដើម្បីជួយដល់ការងារតាមដានរកជំងឺពាក់ព័ន្ធនឹងការផ្ទុះជំងឺនាពេលបច្ចុប្បន្ននេះ រួមទាំងការគ្រប់គ្រងនិងវិភាគទិន្នន័យមន្ទីរពិសោធន៍ផងដែរ។
- ក្រសួងសុខាភិបាលកំពុងអនុវត្តដំណើរការ ផែនការពង្រីក និងធ្វើវិមជ្ឈការសមត្ថភាពនៃមន្ទីរពិសោធន៍សម្រាប់ធ្វើតេស្តរកមេរោគជំងឺកូវីដ១៩ ដល់មន្ទីរពិសោធន៍ខេត្តចំនួន១៣ និងថ្នាក់ជាតិចំនួន ៣។



**បដិសេធការទទួលខុសត្រូវ:** របាយការណ៍នេះមានព័ត៌មាន និងទិន្នន័យដែលត្រឹមត្រូវល្អក្នុងកំឡុងពេលផ្សព្វផ្សាយប៉ុណ្ណោះ។ ដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩ ជាស្ថានការណ៍វិវឌ្ឍន៍ជាប្រចាំ ព័ត៌មាននៅក្នុងឯកសារនេះ អាចនឹងខុសទៅនឹងព័ត៌មានថ្មីៗ។

- អង្គការសុខភាពពិភពលោកផ្តល់ការគាំទ្រដល់ក្រសួងសុខាភិបាល នៅក្នុងការធ្វើបច្ចុប្បន្នភាពយុទ្ធសាស្រ្តថ្នាក់ជាតិសម្រាប់ការធ្វើតេស្តរកវីរុសកូវីដ-១៩ រួមទាំងអានុសាសន៍អំពីសេណារីយ៉ូមួយចំនួនសម្រាប់ពេលដែលគួរប្រើតេស្តរហ័សរកវីរុសកូវីដ-១៩ ហើយបានធ្វើបទបង្ហាញអំពីយុទ្ធសាស្រ្តនោះទៅក្រុមការងារថ្នាក់ជាតិ និងខេត្តនានាដើម្បីស្វែងរកអោយករណីបានឆាប់រហ័ស។
- អង្គការសុខភាពពិភពលោក បានជួយគាំទ្រក្រសួងសុខាភិបាលនៅក្នុងការរៀបចំសំណើរសុំមូលនិធិពីមូលនិធិសកលសម្រាប់គម្រោង C19RM។

## អន្តរគមន៍ និងការផ្តល់សេវាសុខភាព

- ក្រសួងសុខាភិបាល ដោយមានការគាំទ្រពីអង្គការសុខភាពពិភពលោក កំពុងតែធ្វើបច្ចុប្បន្នភាពគោលការណ៍ថ្នាក់ជាតិសម្រាប់ការព្យាបាលអ្នកជំងឺកូវីដ-១៩ ក្រោយពីទទួលបានអនុសាសន៍ពីអង្គការសុខភាពពិភពលោក។
- ក្រសួងសុខាភិបាល ដោយមានការគាំទ្រពីអង្គការសុខភាពពិភពលោក កំពុងរៀបចំបង្កើត:
    - គោលការណ៍ណែនាំសម្រាប់ការបន្តផ្តល់សេវាសុខភាពជាសារវ័ន្តនៅក្នុងអំឡុងពេលនៃការរាតត្បាតដោយជំងឺកូវីដ-១៩។
    - គោលការណ៍ណែនាំអំពីលក្ខខណ្ឌដើម្បីបញ្ចប់ការដាក់អ្នកជំងឺកូវីដ-១៩នៅដាច់ដោយដើម្បីទទួលការព្យាបាល។
    - គោលការណ៍ណែនាំអំពីការផ្តល់ការថែទាំដល់អ្នកជំងឺកូវីដ-១៩។

## ការប្រាស្រ័យទាក់ទងអំពីហានិភ័យ និងការចូលរួមរបស់សហគមន៍

- ក្រសួងសុខាភិបាល និងអង្គការសុខភាពពិភពលោក កំពុងចែកចាយសារជាសម្លេងទៅដល់មន្ទីរសុខាភិបាលតាមបណ្តាខេត្ត។ ហើយខ្លឹមសារនៃសាររួមមាន ការធ្វើតេស្តរកវីរុសកូវីដ-១៩ ក្នុងចំណោមក្រុមប្រជាជនមានហានិភ័យខ្ពស់ សារស្តីអំពីការធ្វើចត្តាឡីស័ក ការពិនិត្យសុខភាពផ្ទាល់ខ្លួន និងវិធានការ៣កុំ និង៣ការពារ។
- សម្ភារៈ និងសារ កំពុងត្រូវបានរៀបចំឡើង និងផ្សព្វផ្សាយ៖
    - សម្ភាររួមទាំងសារជាសម្លេងសម្រាប់ការប្រាស្រ័យទាក់ទងអំពីហានិភ័យនៅតាមរោងចក្រ។
- ក្រសួងសុខាភិបាល ដោយមានការគាំទ្រពីអង្គការសុខភាពពិភពលោក អង្គការយូនីសេហ្វ និង GIZ កំពុងអនុវត្តផែនការជម្រុញការការចូលរួមរបស់សហគមន៍ និងការប្រាស្រ័យទាក់ទងអំពីវ៉ាក់សាំង ជាផ្នែកមួយនៃផែនការចែកចាយវ៉ាក់សាំងថ្នាក់ជាតិ។

## អន្តរគមន៍មិនមែនវេជ្ជសាស្រ្ត

- រដ្ឋាភិបាលកំពុងវាយតម្លៃជាបន្តបន្ទាប់នូវការកែសម្រួលអន្តាគមន៍មិនមែនវេជ្ជសាស្រ្ត តាមរយៈវិធីសាស្រ្តជាជំហាន បន្តិចម្តងៗ ដោយគិតពីប្រសិទ្ធភាព ផលប៉ះពាល់ផ្នែកសេដ្ឋកិច្ច និងសង្គម និងការទទួលយកបានរបស់ប្រជាពលដ្ឋនូវវិធានការនីមួយៗ ខណៈដែលរដ្ឋាភិបាលកំពុងបង្កើនសមត្ថភាពតាមដានជំងឺដើម្បីប្រមូលព័ត៌មានយកទៅធ្វើសេចក្តីសម្រេចចិត្តឲ្យបានត្រឹមត្រូវ។



**បដិសេធការទទួលខុសត្រូវ:** របាយការណ៍នេះមានព័ត៌មាន និងទិន្ន័យដែលត្រឹមត្រូវល្អក្នុងកំឡុងពេលផ្សព្វផ្សាយប៉ុណ្ណោះ។ ដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩ ជាស្ថានការណ៍វិវឌ្ឍន៍ជាប្រចាំ ព័ត៌មាននៅក្នុងឯកសារនេះ អាចនឹងខុសទៅនឹងព័ត៌មានថ្មីៗ។

# ការវាយតម្លៃពីការឆ្លង

ការវាយតម្លៃការតាមដានជំងឺដោយប្រើព័ត៌មានពីច្រើនប្រភពបច្ចុប្បន្ន បង្ហាញថា រាជធានីភ្នំពេញ និងខេត្តព្រះសីហនុស្ថិតនៅក្នុងដំណាក់កាលឆ្លងទី២ (ការឆ្លងសហគមន៍នៅតាមតំបន់) ហើយខេត្តចំនួន២២ផ្សេងទៀត (ខេត្តកណ្តាល ព្រៃវែង ស្វាយរៀង កោះកុង កំពង់ចាម កំពង់ឆ្នាំង កំពង់ធំ សៀមរាប បាត់ដំបង តាកែវ កែប កំពត ខេត្តត្បូងឃ្មុំ ក្រចេះ ប៉ៃលិន ពោធិសាត់ កំពង់ស្ពឺ ខេត្តព្រះវិហារ បន្ទាយមានជ័យ ខេត្តមណ្ឌលគិរី ឧត្តរមានជ័យ និងខេត្តស្ទឹងត្រែង) មានករណីស្ថិតនៅក្នុងដំណាក់កាលឆ្លងទី១ ហើយខេត្តរតនគិរី មិនទាន់មានករណីឆ្លងនោះទេ។

ភស្តុតាងបញ្ជាក់ថា ចំនួនករណីឆ្លងថ្មីមិនទាន់ថមថយនៅឡើយទេ នៅក្នុងភូមិសាស្រ្តរាជធានីភ្នំពេញ។ ការកើនឡើងនៃករណីពិគ្រោះជំងឺស្រដៀងផ្តាសាយ ការថយចុះនៃអ្នកពិនិត្យជំងឺក្រៅ ព្រមទាំងទិន្នន័យនៃការធ្វើតេស្ត បង្ហាញថាការឆ្លងជំងឺបានបន្តឆ្លង។ និន្នាការកើនឡើងនៃករណីឆ្លងថ្មីនៅរាជធានីភ្នំពេញ គឺដោយសារតែការផ្ទុះឡើងនៃជំងឺកូវីដ-១៩នៅក្នុងចំណោមកម្មករកម្មការិនីតាមរោងចក្រ និងនៅក្នុងចំណោមអាជីវករលក់ដូរតាមផ្សារ។ ការចាប់ផ្តើមរោគសញ្ញា និងទិន្នន័យពីការធ្វើតេស្ត បង្ហាញថា ការឆ្លងជំងឺទំនងជាបានកើតឡើងអំឡុងពេល ១០ទៅ ១៤ថ្ងៃមុនពេលថ្ងៃរាយការណ៍។ ទិន្នន័យការធ្វើបម្លាស់ទី បង្ហាញថា គោលនយោបាយលាយបញ្ចូលគ្នា (អ្នកមានចំណូលខ្ពស់ និងអ្នកមានចំណូលទាប) តាមរយៈគម្រោងអភិវឌ្ឍន៍ផ្សេងៗ បានកាត់បន្ថយការចម្លងជំងឺ ហើយប្រហែលជាអាចបន្តធ្លាក់ចុះនៃការឆ្លង ប្រសិនបើត្រូវបន្តទៅទៀត។ នៅក្នុងភូមិសាស្រ្តខេត្តព្រះស៊ីហនុ ភស្តុតាងបង្ហាញថា ការឆ្លងកំពុងរាលដាលនៅក្នុងសហគមន៍។ ការកើនឡើងនូវចំនួនករណីវិជ្ជមាន និងការកើនឡើងនៃចំនួនតេស្ត ផ្តល់ជាសញ្ញាបង្ហាញថាចំនួនករណីឆ្លងកើនឡើង។ មានការប្រែប្រួលនូវភូមិសាស្រ្តនៃការឆ្លងពីតាមបណ្តាកាស៊ីណូ និងក្លិបកម្សាន្ត ទៅតាមទីផ្សារដោយឆ្លងក្នុងចំណោមប្រជាជនទូទៅវិញ។ ការចម្លងមានទម្រង់ស្រដៀងនេះ បានកើតមានឡើងនៅក្នុងរាជធានីភ្នំពេញកាលពី៤សប្តាហ៍មុន។

ជារួម មានការធ្លាក់ចុះនូវចំនួនករណីបានមកពីប្រព័ន្ធតាមដានជំងឺផ្អែកតាមព្រឹត្តិការណ៍រាយការណ៍តាមបណ្តាញទូរស័ព្ទទាន់ហេតុការណ៍ ១១៥ និង បានមកពីប្រព័ន្ធតាមដានជំងឺផ្អែកតាមសូចនាករ (CamEWARN)។ សេចក្តីរាយតាមប្រព័ន្ធផ្សព្វផ្សាយនានា បង្ហាញពីបញ្ហាប្រឈមនៅក្នុងការ អនុវត្តវិធានការអន្តរាគមន៍មិនមែនវេជ្ជសាស្រ្តនានា ជាពិសេសវិធានការរឹតបន្តឹងការធ្វើដំណើរ ។

| បច្ចុប្បន្នភាពអេពីដេមីសាស្រ្តអំពីកូវីដ-១៩ | ចំនួនតេស្ត | ករណីឈឺ | ករណីស្លាប់ | |
|---|---|---|---|---|
| | 56,355<br>ចំនួនតេស្តអាស៊ីតនុយក្លេអ៊ិចក្នុងពេល៧ថ្ងៃចុងក្រោយ | 4,806<br>ករណីវិជ្ជមានថ្មីក្នុងពេល៧ថ្ងៃចុងក្រោយ<br>(៣៩,៥ ភាគរយ - ៧ថ្ងៃ) | 27<br>ករណីស្លាប់ក្នុងពេល៧ថ្ងៃចុងក្រោយ<br>(-២០ ភាគរយ - ៧ថ្ងៃ) | 23<br>ករណីនាំចូលក្នុងពេល២៨ថ្ងៃចុងក្រោយ |
| | 855, 210<br>ចំនួនតេស្តអាស៊ីតនុយក្លេអ៊ិចសរុប | 15,361<br>ករណីសរុប | 106<br>ករណីស្លាប់សរុប | |

| ការផ្តល់សេវាសុខភាពអំពីកូវីដ-១៩ | | | |
|---|---|---|---|
| | 27<br>ចំនួនមន្ទីរពេទ្យដែលទទួលព្យាបាលអ្នកជំងឺកូវីដ-១៩ | 13,782<br>ចំនួនគ្រែមន្ទីរពេទ្យរដ្ឋ | 37<br>ចំនួនមន្ទីរពេទ្យដែលមានបទពិសោធន៍គ្រប់គ្រងករណីជំងឺកូវីដ-១៩<br>(រួមបញ្ចូលមូលដ្ឋានសុខភាពប្រើជាមណ្ឌលព្យាបាលអ្នកជំងឺកូវីដ-១៩ ចំនួន១០) |



**បដិសេធការទទួលខុសត្រូវៈ** របាយការណ៍នេះមានព័ត៌មាន និងទិន្ន័យដែលត្រឹមត្រូវល្អក្នុងកំឡុងពេលផ្សព្វផ្សាយប៉ុណ្ណោះ។ ដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩ ជាស្ថានការណ៍វិវឌ្ឍន៍ជាប្រចាំ ព័ត៌មាននៅក្នុងឯកសារនេះ អាចនឹងខុសទៅនឹងព័ត៌មានថ្មីៗ។

# អេពីដេមីសាស្ត្រ

**ក្រាហ្វិកទី១. ខ្សែកោងអេពីដេមីសាស្ត្រនៃករណីជំងឺកូវីដ-១៩ បែងចែកតាមកាលបរិច្ឆេទនៃរបាយការណ៍**




**តារាងទី១. តារាងនៃករណីឈឺសរុប និងថ្មី (ក្នុងរយៈពេល៧ថ្ងៃចុងក្រោយ) និងករណីស្លាប់ បែងចែកតាមអាយុ និងភេទ**

| ក្រុមនៃអាយុ | ស្រី | | ប្រុស | | សរុប |
|---|---|---|---|---|---|
| | ករណីឈឺ | ករណីស្លាប់ | ករណីឈឺ | ករណីស្លាប់ | ករណីឈឺ |
| 0-9 | **367(150)** | **0(0)** | **342(138)** | **0(0)** | **709(288)** |
| 10-19 | **814(272)** | **0(0)** | **600(218)** | **0(0)** | **1414(490)** |
| 20-29 | **2876(965)** | **2(1)** | **2044(664)** | **3(1)** | **4920(1629)** |
| 30-39 | **2678(843)** | **3(2)** | **2038(604)** | **11(2)** | **4716(1447)** |
| 40-49 | **1098(309)** | **5(1)** | **823(207)** | **13(2)** | **1921(516)** |
| 50-59 | **574(163)** | **10(3)** | **393(90)** | **12(2)** | **967(253)** |
| 60-69 | **270(62)** | **12(2)** | **183(45)** | **9(3)** | **453(107)** |
| 70-79 | **110(39)** | **11(3)** | **76(17)** | **8(3)** | **186(56)** |
| 80-89 | **21(7)** | **3(0)** | **19(7)** | **2(1)** | **40(14)** |
| 90+ | **0(0)** | **0(0)** | **0(0)** | **1(1)** | **0(0)** |
| មិនដឹង | **10(0)** | **0(0)** | **15(1)** | **1(0)** | **35(6)*** |
| សរុប | **8,818(2,810)** | **46(12)** | **6,533 (1,991)** | **60(15)** | **15,361(4,806)** |

*ដោយរាប់បញ្ចូលទាំងករណីដែលមិនដឹងប្រភេទ (n=9).



**បដិសេធការទទួលខុសត្រូវ:** របាយការណ៍នេះមានព័ត៌មាន និងទិន្នន័យដែលត្រឹមត្រូវល្អក្នុងកំឡុងពេលផ្សព្វផ្សាយប៉ុណ្ណោះ។ ដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩ ជាស្ថានការណ៍វិវឌ្ឍន៍ជាប្រចាំ ព័ត៌មាននៅក្នុងឯកសារនេះ អាចនឹងខុសទៅនឹងព័ត៌មានថ្មីៗ។

**ក្រាហ្វិកទី២. ចំនួនសមាមាត្រនៃករណីឈឺបញ្ជាក់ដោយមន្ទីរពិសោធន៍ បែងចែកតាមក្រុមអាយុ និងសញ្ជាតិ (ចំនួន ១៥.៣៦១ នាក់)**




**ក្រាហ្វិកទី៣. ចំនួនករណីជំងឺស្រដៀងផ្តាសាយ (ILI) មកពីកន្លែងតាមដានជំងឺស្រដៀងផ្តាសាយ (ចំនួន ៧កន្លែង) ប្រចាំសប្តាហ៍ ឆ្នាំ ២០២១ និងពីឆ្នាំ២០១៨ ដល់ឆ្នាំ ២០២០**






**បដិសេធការទទួលខុសត្រូវ:** របាយការណ៍នេះមានព័ត៌មាន និងទិន្នន័យដែលត្រឹមត្រូវល្អក្នុងកំឡុងពេលផ្សព្វផ្សាយប៉ុណ្ណោះ។ ដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩ ជាស្ថានការណ៍វិវឌ្ឍន៍ជាប្រចាំ ព័ត៌មាននៅក្នុងឯកសារនេះ អាចនឹងខុសទៅនឹងព័ត៌មានថ្មីៗ។

**ក្រាហ្វិកទី៤. ចំនួនករណីជំងឺរលាកផ្លូវដង្ហើមស្រួចស្រាវធ្ងន់ធ្ងរ ប្រចាំសប្តាហ៍ ឆ្នាំ២០២១ និងពីឆ្នាំ២០១៨ ដល់២០២០**




# អភិក្រមយុទ្ធសាស្រ្ត

**ការឆ្លើយតបសុខភាពសាធារណៈនៅថ្នាក់ជាតិ និងរាជធានី-ខេត្ត**

## ប្រព័ន្ធគ្រប់គ្រងឧប្បត្តិហេតុ

- គណៈកម្មាធិការអន្តរក្រសួង ដែលដឹកនាំដោយរដ្ឋមន្ត្រីក្រសួងសុខាភិបាល និងជាមួយនឹងរដ្ឋលេខាធិការ
    - អនុគណៈកម្មការធិការមួយដឹកនាំដោយអគ្គមេបញ្ជាការរងនៃកងយោធពលខេមរភូមិន្ទ មេបញ្ជាការកងទ័ពជើងគោក
- គណៈកម្មាធិការជាតិប្រយុទ្ធនឹងជំងឺកូវីដ១៩ ដែលដឹកនាំដោយសម្តេចតេជោនាយករដ្ឋមន្ត្រី
- គណៈកម្មាធិការប្រយុទ្ធនឹងជំងឺកូវីដ១៩ថ្នាក់រាជនានី-ខេត្ត ដែលដឹកនាំដោយអភិបាលនៃគណៈអភិបាលរាជធានី-ខេត្ត
- គណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយមានក្រុមការងារបច្ចេកទេស៤ក្រុមសម្រាប់ដោះស្រាយផលប៉ះបាល់ផ្នែកសេដ្ឋកិច្ច និងសង្គមបង្កឡើងដោយជំងឺកូវីដ-១៩

## ការអភិវឌ្ឍប្រព័ន្ធ និងគោលនយោបាយ

- កាលពីថ្ងៃទី៥ ខែមីនា ឆ្នាំ ២០២១ សេចក្តីព្រៀងច្បាប់ស្តីអំពីវិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត ត្រូវបានអនុម័តដោយរដ្ឋសភា។
- ច្បាប់ស្តីពីការគ្រប់គ្រងប្រទេសជាតិស្ថិតក្នុងភាពអាសន្ន ដែលត្រូវបានប្រកាសឲ្យប្រើដោយព្រះរាជក្រិត្យនៅថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២០ មិនទាន់ត្រូវបានអនុវត្តនៅឡើយទេ។
- ទំរង់ Go.Data (Go.Data Platform) ត្រូវបានប្រើជាមូលដ្ឋានទិន្នន័យមួយសម្រាប់ប្រមូលព័ត៌មានអំពីអ្នកប៉ះពាល់ជាមួយករណីកូវីដ-១៩វិជ្ជមាន និងព័ត៌មានមន្ទីរពិសោធន៍។
- មូលដ្ឋានទិន្នន័យរបស់វិទ្យាស្ថានជាតិសុខភាពសាធារណៈ និងនាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង ត្រូវបានកែសម្រួលដើម្បីអាចបញ្ចូលសំណុំទិន្នន័យប្រភពច្រើនសម្រាប់ការធ្វើតេស្ត និងតាមដានជំងឺ។

## គន្លឹះអាទិភាពសំខាន់ៗ

- អង្គការសុខភាពពិភពលោកកំពុងធ្វើបច្ចុប្បន្នភាពយុទ្ធសាស្រ្តឆ្លើយតបចំពោះជំងឺកូវីដ-១៩ថ្នាក់ជាតិសម្រាប់ឆ្លើយតបទៅនឹងការរាតត្បាតនៃជំងឺពេលបច្ចុប្បន្ននេះ។



**បដិសេធការទទួលខុសត្រូវៈ** របាយការណ៍នេះមានព័ត៌មាន និងទិន្នន័យដែលត្រឹមត្រូវល្អក្នុងកំឡុងពេលផ្សព្វផ្សាយប៉ុណ្ណោះ។ ដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩ ជាស្ថានការណ៍វិវឌ្ឍន៍ជាប្រចាំ ព័ត៌មាននៅក្នុងឯកសារនេះ អាចនឹងខុសទៅនឹងព័ត៌មានថ្មីៗ។

- នាយកដ្ឋានមន្ទីរពេទ្យនៃក្រសួងសុខាភិបាល កំពុងធ្វើការស្ទង់មតិមួយអំពីវគ្គបណ្តុះបណ្តាលកន្លងមកពីការគ្រប់គ្រងគ្លីនិក ការបង្ការនិងត្រួតពិនិត្យការឆ្លងរោគ ដើម្បីរៀបចំបង្កើតកម្មវិធីសិក្សាថ្នាក់ជាតិមួយសំរាប់បញ្ហាជំងឺកូវីដ-១៩។
- នាយកដ្ឋានមន្ទីរពេទ្យនៃក្រសួងសុខាភិបាល កំពុងធ្វើការវាយតម្លៃទាក់ទងនឹងការត្រៀមខ្លួនរបស់ប្រព័ន្ធសុខាភិបាល នៅតាមមូលដ្ឋានថែទាំសុខភាព ទាក់ទងនឹងសមត្ថភាពសង្គ្រោះបន្ទាន់ (ICU) អុកស៊ីសែន បុគ្គលិកសុខាភិបាលជាដើម។
- កម្មវិធីថ្នាក់ជាតិកំពុងតែអភិវឌ្ឍផែនការឆ្លើយតប និងត្រៀមបង្ការដោយផ្តោតជាសំខាន់ទៅលើជំងឺកូវីដ-១៩។
- កំពុងដាក់ឲ្យអនុវត្តយុទ្ធសាស្ត្រពង្រីកមន្ទីរពិសោធន៍ និងផែនការធ្វើរោគវិនិច្ឆ័យម៉ូលេគុលដើម្បីធានាឲ្យមានការធ្វើតេស្តគ្រប់គ្រាន់ជាប្រចាំសម្រាប់ជំងឺកូវីដ-១៩នៅថ្នាក់ជាតិ និងថ្នាក់តំបន់។
- ការបង្កើតផែនការអនុវត្តន៍សម្រាប់ការប្រើប្រាស់ការតាមដានជំងឺដោយប្រើពហុប្រភពព័ត៌មាននៅកម្រិតថ្នាក់ក្រោមជាតិសម្រាប់វាយតម្លៃហានិភ័យ និងការធ្វើសេចក្តីសម្រេចចិត្ត។
- ពង្រឹងសមត្ថភាពត្រៀមបង្ការនៅថ្នាក់មូលដ្ឋាន ក្នុងករណីមានការផ្ទុះរាលដាលជំងឺនៅសហគមន៍នាពេលអនាគត និងដើម្បីកាត់បន្ថយការរាំងស្ទះដល់ដំណើរការផ្តល់សេវាសុខភាពសំខាន់ៗ។

## អភិក្រមយុទ្ធសាស្ត្រសម្រាប់បង្ការ ស្រាវជ្រាវ និងត្រួតពិនិត្យជំងឺកូវីដ-១៩

- *យុទ្ធសាស្ត្រសម្រាប់ការធ្វើតេស្ត និងប្រព័ន្ធស្វែងរកអ្នកប៉ះពាល់មានរួចរាល់*

យុទ្ធសាស្ត្រធ្វើតេស្តទូលំទូលាយមួយ កំពុងត្រូវបានអនុវត្តនៅទូទាំងប្រទេស ដែលរួមមានការធ្វើតេស្តករណីសង្ស័យទាំងអស់ដែលចូលក្នុងនិយមន័យករណីសង្ស័យមានជំងឺកូវីដ-១៩ និងការឃ្លាំមើលយ៉ាងសកម្មចំពោះករណីជំងឺរលាកសាច់សួត (pneumonia) នៅតាមមន្ទីរពេទ្យ ក៏ដូចជាការធ្វើតេស្តនៅច្រកចេញ-ចូល (points of entry) នាថ្ងៃទី១ និងថ្ងៃទី១៣ ពេលបញ្ចប់ចត្តាឡីស័ក១៤ ថ្ងៃ និងការធ្វើតេស្តវត្ថុវិភាគបានមកពីប្រព័ន្ធតាមដានមានស្រាប់នៃជំងឺស្រដៀងផ្តាសាយ (ILI) និងជំងឺផ្លូវដង្ហើមស្រួចស្រាវធ្ងន់ធ្ងរ (SARI) ដើម្បីកំណត់រកមេរោគកូវីដ-១៩។ យុទ្ធសាស្ត្រតាមដានជំងឺ កំពុងត្រូវបានអនុវត្តនៅពេលចាំបាច់ នៅតាមតំបន់ដែលប្រឈមខ្ពស់ ឬតំបន់ដែលមានករណីវីរុសកូវីដ-១៩ ច្រើន (Hot-spot surveillance strategies) ក៏ដូចការធ្វើតេស្តទៅលើក្រុមប្រជាជនដែលមានហានិភ័យខ្ពស់ (high-risk populations)។

- *ការប្រាស្រ័យទាក់ទងអំពីហានិភ័យ និងការចូលរួមរបស់សគមន៍*

យុទ្ធសាស្ត្រសម្រាប់ស្រាវជ្រាវរកជំងឺដោយមានការចូលរួមរបស់សហគមន៍ ត្រូវបានបង្កើតឡើង និងដាក់សាកល្បងដើម្បីស្វែករកករណីជំងឺកូវីដ-១៩ នៅកម្រិតមណ្ឌលសុខភាប និងសហគមន៍។ ក្រសួងមហាផ្ទៃ កំពុងជម្រុញការត្រួតពិនិត្យនៅតាមមណ្ឌលចត្តាឡីស័កតាមរយៈការតាមដាន និងពិន័យសម្រាប់បុគ្គលដែលបំពានគោលការណ៍ណែនាំ។ យុទ្ធសាស្ត្រជម្រុញការចូលរួមរបស់សហគមន៍កំពុងត្រូវបានបង្កើតឡើង ហើយក្រសួងសុខាភិបាលបានបង្កើតផែនការគ្រប់គ្រង និងតាមដានការចូលរួម និងការប្រាស្រ័យទាក់ទងជាសហគមន៍ ដែលត្រូវអនុវត្តពីខែឧសភា ដល់ខែកក្កដាឆ្នាំ២០២០ សម្រាប់បុគ្គលិកសុខាភិបាល និងបុគ្គលិកភូមិនៅក្នុងខេត្តចំនួន១២។

- *អន្តរាគមន៍សុខភាពសាធារណៈមិនមែនវេជ្ជសាស្ត្រ (មាននៅក្នុងតារាងនៅចុងបញ្ចប់នៃរបាយការណ៍នេះ)*

# បទពិសោធន៍ល្អៗ និងមេរៀនដែលទទួលបាន

## កត្តាដែលបានរួមចំណែកដល់ការឆ្លើយតបបានល្អ

- **ភាពជាអ្នកដឹកនាំខ្លាំង និងការសម្របសម្រួលបានល្អ**
    - ការឆ្លើយតបរបស់រដ្ឋាភិបាល និងសង្គមទាំងមូល ដឹកនាំដោយសម្តេចតេជោនាយករដ្ឋមន្ត្រី ហើយវិធានការសុខភាពសាធារណៈដឹកនាំដោយរដ្ឋមន្ត្រីសុខាភិបាល។



**បដិសេធការទទួលខុសត្រូវៈ** របាយការណ៍នេះមានព័ត៌មាន និងទិន្នន័យដែលត្រឹមត្រូវល្អក្នុងកំឡុងពេលផ្សព្វផ្សាយប៉ុណ្ណោះ។ ដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩ ជាស្ថានការណ៍វិវឌ្ឍន៍ជាប្រចាំ ព័ត៌មាននៅក្នុងឯកសារនេះ អាចនឹងខុសទៅនឹងព័ត៌មានថ្មីៗ។

- ផែនការមេថ្នាក់ជាតិសម្រាប់ប្រយុទ្ធនឹងជំងឺកូវីដ-១៩ ត្រូវបានរៀបចំឡើងជាមួយនឹងថវិកាចំនួន ៦២លានដុល្លារសហរដ្ឋអាមេរិកសម្រាប់ឆ្នាំទី១។

- **ការវិនិយោគកន្លងមកបានពង្រឹងដំណើរការប្រព័ន្ធសុខភាពសុខភាពសាធារណៈ**
  - ការតាមដានជំងឺកូវីដ-១៩ ដោយបានពីព័ត៌មានពហុប្រភព រួមទាំងប្រព័ន្ធឃ្លាំមើលជំងឺកូវីដ-១៩ ដោយប្រើប្រព័ន្ធទូរស័ព្ទទាន់ហេតុការណ៍ (១១៥) និងប្រព័ន្ធតាមដានមានស្រាប់នៃជំងឺស្រដៀងផ្តាសាយ (ILI) និងជំងឺរលាកផ្លូវដង្ហើមស្រួចស្រាវធ្ងន់ធ្ងរ (SARI)។
  - ក្រុមឆ្លើយតបបន្ទាន់ជិត ៣.០០០នាក់ នៅទូទាំងប្រទេស បានស្រាវជ្រាវរកករណី និងតាមរកអ្នកប៉ះពាល់ជាមួយនឹងករណីវិជ្ជមានវីរុសកូវីដ-១៩។
- **ការទំនាក់ទំនង និងផ្សព្វផ្សាយហានិភ័យ និងការចូលរួមរបស់សហគមន៍**
  - សារទាន់ពេលវេលា ត្រូវបានផ្សព្វផ្សាយតាមទូរទស្សន៍ វិទ្យុ និងបណ្តាញសង្គម និងតាមរយៈសេចក្តីជូនព័ត៌មានទៀងទាត់ និងសន្និសីទសារព័ត៌មាន។
  - សម្ភារទំនាក់ទំនងសម្រាប់ទស្សនិកជន និងអ្នកស្តាប់គោលដៅ ត្រូវបានបង្កើតឡើងសម្រាប់ក្រុមដែលមានហានិភ័យខ្ពស់ ដូចជាជនទេសន្តប្រវេសន៍(ពលករចំណាកស្រុក) និងកម្មកររោងចក្រ។
  - យុទ្ធសាស្ត្រជម្រុញការចូលរួមរបស់សហគមន៍ ត្រូវបានអនុវត្តដើម្បីគ្របដណ្តប់គ្រប់ផ្នែកនៃការតាមដានជំងឺ និងការឆ្លើយតបចំពោះជំងឺកូវីដ-១៩ ជាពិសេសត្រៀមសម្រាប់ពេលមានការឆ្លងទៅសហគមន៍ណាមួយ។
- **សាមគ្គីភាព និងសហប្រតិបត្តិការអន្តរជាតិ**
  - ការឆ្លើយតបដោយប្រព័ន្ធសុខាភិបាលមួយដែលមានតម្លាភាព និងបើកចំហ។
  - កិច្ចសហការបច្ចេកទេស និងប្រតិបិត្តិការជិតស្និទ្ធរវាងទីភ្នាក់ងារអង្គការសហប្រជាជាតិ និងដៃគូអភិវឌ្ឍន៍ដទៃទៀត។
  - ការចូលរួមនៃមន្ត្រីជាន់ខ្ពស់នៅកិច្ចប្រជុំអន្តរជាតិនានា រួមទាំងការសម្របសម្រួលជាទៀងទាត់ក្នុងចំណោមបុគ្គលិកទទួលបន្ទុកផ្នែកច្បាប់និយ័តកម្មអន្តរជាតិឆ្នាំ២០០៥ របស់អង្គការសុខភាពពិភពលោក។

## ការចាក់វ៉ាក់សាំងកូវីដ-១៩

- គិតត្រឹមថ្ងៃទី ០៣ ខែឧសភា ឆ្នាំ២០២១ បុគ្គលចំនួន ១.៤៦៥.៩៩៥ បានទទួលវ៉ាក់សាំងការពារជំងឺកូវីដ-១៩ដូសទី១ និងបុគ្គលចំនួន ១.០០៣.៨៣៧ បានទទួលវ៉ាក់សាំងដូសទី២។ អត្រាទទួលបានវ៉ាក់សាំងដូសទីមួយ គឺ៩ភាគក្នុងចំណោមប្រជាជនសរុបគ្រោងនឹងទទួលបានការចាក់វ៉ាក់សាំង និងដូសទីពីរគឺ៨ភាគរយនៃប្រជាជនគោលដៅដែលគ្រោងទទួលបានការចាក់វ៉ាក់សាំង។ ក្នុងចំណោមអ្នកដែលបានទទួលវ៉ាក់សាំងដូសទីមួយមានស្ត្រីប្រមាណ ៤៤ភាគរយ និង ក្នុងចំណោមអ្នកដែលបានចាក់វ៉ាក់សាំងដូសទីពីរមានស្ត្រី ៣៩ភាគរយ។
- គិតត្រឹមថ្ងៃទី ០៣ ខែឧសភា ឆ្នាំ២០២១ មានព្រឹត្តិការណ៍មិនល្អក្រោយពេលចាក់វ៉ាក់សាំង (AEFI) ចំនួន ១១៦ករណី ត្រូវបានរាយការណ៍ពីខេត្តចំនួន ២០ និងមន្ទីរពេទ្យជាតិចំនួន ២។ ក្រសួងសុខាភិបាល កំពុងតែតាមដានយ៉ាងយកចិត្តទុកដាក់ និងស៊ើបអង្កេតករណីព្រឹត្តិការមិនល្អក្រោយពេលចាក់វ៉ាក់សាំង។
- វ៉ាក់សាំងស៊ីណូវ៉ាក់ចំនួន ១លានដូស ត្រូវបានរំពឹងថានឹងមកដល់ប្រទេសកម្ពុជានៅថ្ងៃទី ១០ ខែឧសភា ឆ្នាំ២០២១។
- រាជរដ្ឋាភិបាលកម្ពុជា បានសម្រេចពន្លឿនយុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩ នៅទីក្រុងភ្នំពេញ ជាពិសេសសម្រាប់ពលរដ្ឋរស់នៅតំបន់ក្រហមដែលត្រូវបានកំនត់ថាមានហានិភ័យខ្ពស់។ ចាប់ពីថ្ងៃទី ១ រហូតដល់ថ្ងៃទី ៣ ខែឧសភា ឆ្នាំ២០២១ បុគ្គលចំនួន ១០០.៣៥៧ ដែលរស់នៅតំបន់ក្រហម បានទទួលវ៉ាក់សាំងប្រឆាំងនឹងជំងឺកូវីដ-១៩ដូសទី១។



**បដិសេធការទទួលខុសត្រូវ:** របាយការណ៍នេះមានព័ត៌មាន និងទិន្នន័យដែលត្រឹមត្រូវល្អក្នុងកំឡុងពេលផ្សព្វផ្សាយប៉ុណ្ណោះ។ ដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩ ជាស្ថានការណ៍វិវឌ្ឍន៍ជាប្រចាំ ព័ត៌មាននៅក្នុងឯកសារនេះ អាចនឹងខុសទៅនឹងព័ត៌មានថ្មីៗ។

## អន្តរាគមន៍សុខភាពសាធារណៈមិនមែនឱសថ (Non-Pharmaceutical Interventions, NPIs)

- កាលពីថ្ងៃទី ២៥ ខែមេសា ឆ្នាំ២០២១ រាជរដ្ឋាភិបាលកម្ពុជា បានសម្រេចបញ្ចប់ការហាមឃាត់ការធ្វើដំណើរឆ្លងរាជធានី-ខេត្តលើកលែងរាជធានីភ្នំពេញ និងទីក្រុងតាខ្មៅ។
- កាលពីថ្ងៃទី ១៧ ខែមេសា ឆ្នាំ២០២១ រាជរដ្ឋាភិបាលបានចេញសេចក្តីសម្រេចស្តីអំពីការកែសម្រួលវិធានការដែលត្រូវអនុវត្តក្នុងអំឡុងពេលបិទខ្ទប់ភូមិសាស្ត្ររាជធានីភ្នំពេញ និងក្រុងតាខ្មៅនៃខេត្តកណ្តាល។
- កាលពីថ្ងៃទី ១៤ ខែមេសា ឆ្នាំ២០២១ រាជរដ្ឋាភិបាលបានចេញសេចក្តីសម្រេចស្តីអំពីការបិទខ្ទប់ភូមិសាស្ត្ររាជធានីភ្នំពេញ និងក្រុងតាខ្មៅនៃខេត្តកណ្តាល ដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ដោយអនុវត្តចាប់ពីថ្ងៃទី១៥ រហូតដល់ថ្ងៃទី ២៨ ខែមេសា ឆ្នាំ២០២១ ។
- កាលពីថ្ងៃទី ១៧ ខែមេសា ឆ្នាំ២០២១ រាជរដ្ឋាភិបាលបានចេញសេចក្តីសម្រេចស្តីអំពីការបន្តហាមឃាត់ការធ្វើដំណើរ និងបិទរមណីយដ្ឋានទេសចរណ៍នៅទូទាំងប្រទេសជាបណ្តោះអាសន្នដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ រហូតដល់ថ្ងៃទី ២៨ ខែមេសា ឆ្នាំ២០២១ ។
- កាលពីថ្ងៃទី ១១ ខែមេសា ឆ្នាំ២០២១ រាជរដ្ឋាភិបាលកម្ពុជា បានចេញអនុក្រឹត្យស្តីអំពីកាតព្វកិច្ចក្នុងការទទួលការចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ សម្រាប់៖
    - មន្ត្រីរាជការសាធារណៈ និងកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ
    - ពលរដ្ឋទទួលអាណត្តិសាធារណៈដោយការបោះឆ្នោត និងមន្ត្រីរាជការសាធារណៈនៅស្ថាប័នព្រឹទ្ធសភា រដ្ឋសភា និងស្ថាប័នតុលាការ
    - សម្រាប់បុគ្គលមួយចំនួនផ្សេងទៀតដោយផ្អែកលើស្ថានភាពនៃការងារ ឬស្ថានភាពនៃមុខរបររបស់បុគ្គលនោះតាមការកំណត់របស់ក្រសួងសុខាភិបាល។
- រាជរដ្ឋាភិបាល បានអនុវត្តការហាមការធ្វើដំណើរឆ្លងកាត់ ចេញ-ចូលពីខេត្តមួយទៅខេត្តមួយជាបណ្តោះអាសន្នពីថ្ងៃទី ០៧ រហូតដល់ ថ្ងៃទី ២០ ខែមេសា ឆ្នាំ២០២១។
- រដ្ឋបាលរាជធានីភ្នំពេញ ខេត្តសៀមរាប ខេត្តកំពង់ស្ពឺ ខេត្តពោធិសាត់ ខេត្តឧត្តរមានជ័យ ខេត្តបន្ទាយមានជ័យ និងរដ្ឋបាលខេត្តក្រចេះ បានសម្រេចអនុវត្តបម្រាមគោចរចាប់ពីម៉ោង ៨យប់ រហូតដល់ម៉ោង ៥ព្រឹក។
- កាលពីថ្ងៃទី ២៧ ខែមីនា ឆ្នាំ២០២១ សាលារាជធានីភ្នំពេញ បានចេញបទបញ្ជាតម្រូវឲ្យអនុវត្តកាតព្វកិច្ចពាក់ម៉ាស់ និងរក្សាគម្លាតសុវត្ថិភាពនៅតាមទីសាធារណៈនៅក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ ក្រោយពីរាជរដ្ឋាភិបាលបានចេញអនុក្រឹត្យលើប្រធានបទដូចគ្នា និងលិខិតរបស់ក្រសួងមហាផ្ទៃឲ្យអនុវត្តច្បាប់ អនុក្រឹត្យ និងប្រកាសស្តីអំពីការគ្រប់គ្រងការរាតត្បាតនៃជំងឺកូវីដ-១៩។ ទីកន្លែងដែលត្រូវអនុវត្តកាតព្វកិច្ចពាក់ម៉ាស់ និងរក្សាគម្លាតសុវត្ថិភាព រួមមានសហគ្រាស គ្រឹះស្ថានរដ្ឋ និងឯកជន ភោជនីយដ្ឋាន អាហារដ្ឋាន ផ្ទះសំណាក់ សណ្ឋាគារ គ្លីនិក មន្ទីរពេទ្យឯកជន ឱសថស្ថាន ទីផ្សារ ហាងលក់ទំនិញ ធនាគារ ស្ថាប័នមីក្រូហិរញ្ញវត្ថុ រោងចក្រ សិប្បកម្ម កន្លែងការងារ និងអាជីវកម្មផ្សេងៗ។
- កាលពីថ្ងៃទី ២៥ ខែមីនា រាជរដ្ឋាភិបាលកម្ពុជា បានដាក់ចេញនូវសេចក្តីណែនាំអំពីវិធានការបន្ថែមដើម្បីបន្តគ្រប់គ្រងផលប៉ះពាល់លើវិស័យសំខាន់ៗនៃសេដ្ឋកិច្ចនៅក្នុងបរិការណ៍នៃវិបត្តិ ការស្តារនិងជម្រុញកំណើនសេដ្ឋកិច្ចកម្ពុជាក្នុងអំឡុង និងក្រោយពីវិបត្តិនៃជំងឺកូវីដ-១៩។
    - វិធានការសម្រាប់ជួយដល់កម្មករ-និយោជិតនៃវិស័យកាត់ដេរ-វាយណនភណ្ឌ ស្បែកជើង ផលិតផលធ្វើដំណើរ ការបូប និង វិស័យទេសចរណ៍៖ រាជរដ្ឋាភិបាល នឹងបន្តផ្តល់ប្រាក់ឧបត្ថម្ភ៤០ដុល្លារក្នុងមួយខែដល់កម្មករ-និយោជិត០១នាក់ ហើយម្ចាស់រោងចក្រសហគ្រាសក្នុងវិស័យនេះផ្តល់ ៣០ដុល្លារក្នុងមួយខែបន្ថែមទៀត ពីខែមេសា ដល់ខែមិថុនា ឆ្នាំ២០២១។
    - វិធានការបន្តជួយវិស័យអាកាសចរៈបន្តលើកលែងការបង់ពន្ធអប្បបរមា សម្រាប់រយៈពេលបីខែបន្ថែមទៀត។
    - ការបន្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះ សម្រាប់រយៈពេលបីខែទៀត ។
- កាលពីថ្ងៃទី ២៤ ខែមីនា ឆ្នាំ ២០២១ គណៈកម្មការប្រកួតបាល់ទាត់ជាតិកម្ពុជា បានចេញចេញលិខិតមួយទៅកាន់មន្ទីរអប់រំយុវជន និងកីឡាខេត្តត្បូងឃ្មុំ ឲ្យផ្អាកការប្រកួតនានានៅក្នុងខេត្តរយៈពេលពីរសប្តាហ៍ដើម្បីចូលរួមទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩។



**បដិសេធការទទួលខុសត្រូវ:** របាយការណ៍នេះមានព័ត៌មាន និងទិន្នន័យដែលត្រឹមត្រូវល្អក្នុងកំឡុងពេលផ្សព្វផ្សាយប៉ុណ្ណោះ។ ដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩ ជាស្ថានការណ៍វិវឌ្ឍន៍ជាប្រចាំ ព័ត៌មាននៅក្នុងឯកសារនេះ អាចនឹងខុសទៅនឹងព័ត៌មានថ្មីៗ។

- កាលពីថ្ងៃទី ២៣ ខែមីនា ឆ្នាំ ២០២១ ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ បានចេញវិធានការដើម្បីទប់ស្កាត់ការឆ្លងជំងឺកូវីដ-១៩ នៅពេលប្រារព្ធពិធីបុណ្យចូលឆ្នាំខ្មែរខាងមុននេះ។
- កាលពីថ្ងទី ២៣ ខែមីនា ឆ្នាំ២០២១ ក្រសួងធម្មការ និងកិច្ចការសាសនា បានចេញវិធានការទប់ស្កាត់ការរាលដាលនៃជំងឺកូវីដ-១៩ ក្នុងអំឡុងពេលពិធីបុណ្យចូលឆ្នាំខ្មែរបីថ្ងៃខាងមុខ៖
    - នៅតាមវត្តអារាម វិហារសាសនាគ្រិស្ត និងវិហារសាសនាឥស្លាមទាំងអស់ ត្រូវអនុវត្តវិធានសុខាភិបាលរបស់ក្រសួងសុខាភិបាល ដើម្បីទប់ស្កាត់ការរាលដាលជំងឺកូវីដ-១៩ ដោយរក្សាគម្លាតសុវត្ថិភាព
    - អនុវត្តវិធានការ ៣កុំ និង ៣ការពារ
    - ជៀសវាងរៀបចំពិធីសាសនា ឬការជួបជុំមនុស្សច្រើន និងកន្លែងដែលមានមនុស្សអ៊ូអរ
- កាលពីថ្ងៃទី ២៤ ខែមីនា ឆ្នាំ២០២១ ក្រសួងសុខាភិបាលបានប្រកាសពីភូមិសាស្ត្រដែលត្រូវអនុវត្តកាតព្វកិច្ចពាក់ម៉ាស និងកាតព្វកិច្ចរក្សាគម្លាតសុវត្ថិភាពនៅក្នុងរាជធានី-ខេត្តចំនួន៥ គឺរាជធានីភ្នំពេញ ខេត្តព្រះសីហនុ កណ្ដាល ព្រៃវែង និងខេត្តសៀមរាប។
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ បានប្រកាសបិទរោងកុន និងសារមន្ទីរនៅទូទាំងប្រទេស។
- ក្រសួងអប់រំ យុវជននិងកីឡា បានប្រកាសកាលពីថ្ងៃទី ២០ មីនា ឆ្នាំ២០២១ បិទគ្រឹះស្ថានអប់រំរដ្ឋ និងឯកជនទាំងអស់នៅទូទាំងប្រទេស។
- ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ បានប្រកាសកាលពីថ្ងៃទី ២០ មីនា ឆ្នាំ២០២១ បិទគ្រឹស្ថានអប់រំ បណ្ដុះបណ្ដាលវិជ្ជាជីវៈ និងបច្ចេកទេសនៅទូទាំងប្រទេស។
- កាលពីថ្ងៃទី ១៧ ខែមីនា ឆ្នាំ២០២១ ធម្មការ និងកិច្ចការសាសនា បានប្រកាសផ្អាកជាបណ្ដោះអាសន្ននូវរាល់ពិធី និងការជួបជុំបែបសាសនាទាំងអស់ទូទាំងប្រទេស។
- គិតត្រឹមថ្ងៃទី ១៦ ខែមីនា ឆ្នាំ២០២១ អាជ្ញាធរស្រុកកោះធំ ខេត្តកណ្ដាល បានផ្អាកជាបណ្ដោះអាសន្ននូវអាជីវកម្មគ្រប់ប្រភេទ ដើម្បីជៀសវាងការចម្លងជំងឺទ្រង់ទ្រាយធំណាមួយ។
- គិតត្រឹមថ្ងៃទី ១៥ ខែមីនា ឆ្នាំ២០២១ អាជ្ញាធរខេត្តចំនួន៥ គឺខេត្តស្វាយរៀង ប៉ៃលិន ព្រះវិហារ កំពត និងខេត្តឧត្តរមានជ័យ បានប្រកាសពីការផ្អាកការរៀបចំពិធីអាពាហ៍ពិពាហ៍ ពិធីជប់លៀង និងការជួបជុំបែបសាសនាផ្សេងៗ។
- នៅថ្ងៃទី ១០ មីនា ក្រសួងអប់រំ យុវជន និងកីឡា បានប្រកាសផ្អាកសាលារៀនទាំងអស់ ទាំងរដ្ឋ និងឯកជននៅក្នុងខេត្តព្រៃវែង ចាប់ពីថ្ងៃទី ១០ មីនា តទៅរហូតដល់មានការជូនដំណឹងជាថ្មី។
- កាលពីថ្ងៃទី ៩ ខែមិនា សម្ដេចអគ្គមហាសេនាបតីតេជោហ៊ុនសែន បានផ្ញើសារជាសម្លេងស្នើរឲ្យក្រុមហ៊ុនឯកជនទាំងអស់ បើអាចត្រូវកាត់បន្ថយចំនួនបុគ្គលិកធ្វើការនៅការិយាល័យ ហើយរៀបចំការធ្វើការបែបផ្សេងៗជំនួនវិញដូចជាឆ្លាស់វេនគ្នាទៅធ្វើការជាដើម។
- កាលពីថ្ងៃទី ៩ ខែមីនា រដ្ឋបាលខេត្តកណ្ដាល បានប្រកាសពីការរឹតបន្តឹងការធ្វើដំណើរទៅកាន់ទីប្រជុំជនជ្រៃធំ ខេត្តកណ្ដាល។
- កាលពីថ្ងៃទី ២១កុម្ភៈ ឆ្នាំ២០២១ ក្រសួងសុខាភិបាលបានប្រកាសអំពីការដាក់ប្រើប្រព័ន្ធ QR កូដ "បញ្ឈប់កូវីដ-១៩" បង្កើតដោយក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍។
- នៅថ្ងៃទី ២០ ខែកុម្ភៈ សេចក្ដីប្រកាសព័ត៌មានដោយនាយករដ្ឋមន្ត្រី ជូនដំណឹងអំពី៖
    - ការបិទក្លឹបកំសាន្ត និងទីតាំងផ្សេងៗទៀតនៅជិតតំបន់ដែលមានឆ្លងករណីកូវីដ-១៩
    - លើកទឹកចិត្តឲ្យបុគ្គលដែលពាក់ព័ន្ធនឹងករណីវិជ្ជមានវីរុសកូវីដ-១៩ ករណីឲ្យទៅធ្វើតេស្ត
    - រម្លឹកសាធារណជនអំពីការអនុវត្តបីការពារ និងបីកុំ និងលើកទឹកចិត្តកុំឲ្យមានការរើសអើងចំពោះជនជាតិចិន
    - ដោយត្រូវធ្វើចត្តាឡីស័កចំនួន ១៤ថ្ងៃ ពលករចំណាកស្រុកជនជាតិខ្មែរ ត្រូវបានអំពាវនាវកុំឲ្យត្រលប់ពីប្រទេសថៃមកកម្ពុជាវិញ ដើម្បីចូលរួមអបអរពិធីបុណ្យចូលឆ្នាំខ្មែរនៅខែមេសាខាងមុខ
- កាលពីថ្ងៃទី ២០ ខែកុម្ភៈឆ្នាំ២០២១ ក្រសួងអប់រំ យុវជននិងកីឡា បានចេញសេចក្ដីប្រកាសមួយស្ដីអំពីការរឹតត្បិតលើការអនុវត្តវិធានការសុវត្ថិភាព និងសុខភាព នៅតាមគ្រឹះស្ថានអប់រំសាធារណៈ និងឯកជន នៅទីក្រុងភ្នំពេញ៖
    - ផ្អាកជាបណ្ដោះអាសន្ន នូវការជួបជុំ និងសកម្មភាពកីឡាទាំងឡាយណាដែលមានគ្នាលើសពី២០នាក់
    - បុគ្គលិក ត្រូវបានចាត់តាំងជាអ្នកតំណាងសម្រាប់ទំនាក់ទំនងសម្រាប់ការតាមដានការអនុវត្តវិធានធ្វើចត្តាឡីស័ក



**បដិសេធការទទួលខុសត្រូវ:** របាយការណ៍នេះមានព័ត៌មាន និងទិន្ន័យដែលត្រឹមត្រូវល្អក្នុងកំឡុងពេលផ្សព្វផ្សាយប៉ុណ្ណោះ។ ដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩ ជាស្ថានការណ៍វិវឌ្ឍន៍ជាប្រចាំ ព័ត៌មាននៅក្នុងឯកសារនេះ អាចនឹងខុសទៅនឹងព័ត៌មានថ្មីៗ។

**តារាងទី២ . ការអនុវត្តអន្តរាគមន៍សុខភាពសាធារណៈមិនមែនឱសថ និងថ្ងៃដែលលើកបម្រាមវិញ (NPI implementation and lifting dates)**

| អន្តរាគមន៍សុខភាពសាធារណៈ មិនមែនវេជ្ជសាស្ត្រ( NPI) | ស្ថានភាពត្រួតពិនិត្យ (Monitoring status) | | | | | |
|---|---|---|---|---|---|---|
| | | | ការអនុវត្ត (Implementation) | | ការលើកបម្រាមវិញដោយផ្នែក (Partial lift) | លើកបម្រាមវិញ (Lifted) |
| | ថ្ងៃទី១នៃការអនុវត្ត (Date first implemented) | ថ្ងៃកែប្រែចុងក្រោយ (Date last modified) | ភូមិសាស្ត្រ (ថ្នាក់ជាតិ ឬថ្នាក់ក្រោមជាតិ) Geographical (national or sub-national) | ណែនាំឲ្យ ឬ តម្រូវឲ្យ (Recommended or Required) | លើកសម្រាប់ វិស័យ/ផ្នែកខ្លះ (Lifted for some area) | លើកសម្រាប់វិស័យ/ផ្នែកទាំងអស់ (Lifted for all areas) |
| ពាក់ម៉ាស់ការពារ អនាម័យដៃ និងផ្លូវដង្ហើម | មិនមានទេ (None) | ២៤ មីនា ឆ្នាំ២០២១ | ថ្នាក់ក្រោមជាតិ | តម្រូវឲ្យ (Required) | | មិនទាន់លើកទេ (No) |
| បិទសាលារៀន (School Closure) | ១៦ មិនា ឆ្នាំ២០២០ | ២០ មីនា ឆ្នាំ២០២១ | ថ្នាក់ជាតិ | តម្រូវឲ្យ (Required) | មិនទាន់លើកទេ (No) | មិនទាន់លើកទេ (No) |
| បិទកន្លែងធ្វើការ (Workplace Closure) | មិនមានទេ (None) | មិនមានទេ (None) | | | | |
| ការជួបជុំមនុស្សម្នារច្រើន (Mass Gatherings) | ៣ មេសា ឆ្នាំ២០២០ | ២៩ ធ្នូ ២០២០ | ថ្នាក់ជាតិ | តម្រូវឲ្យ (Required) | មិនទាន់លើកទេ (No) | មិនទាន់លើកទេ (No) |
| នៅផ្ទះ (Stay at Home) | រដ្ឋាភិបាលស្នើឲ្យនៅផ្ទះប្រសិនបើអាចធ្វើបាន (Government recommends stay home if possible) | មិនមានទេ (None) | | | | |
| រឹតបន្តឹងការធ្វើដំណើរនៅក្នុងប្រទេស (Restrictions on Internal Movement (within country)) | ៩ មេសា ឆ្នាំ២០២០ | ២៥ មេសា ឆ្នាំ២០២១ | ថ្នាក់ក្រោមជាតិ | ណែនាំឲ្យ (Recommended) | បានលើកហើយ (Yes) | មិនទាន់លើកទេ (No) |
| ការរឹតបន្តឹងលើការធ្វើដំណើរអន្តរជាតិ (Restrictions on International Travel) | ១៧ មិនា ឆ្នាំ២០២០ | ១១ វិច្ឆិកាឆ្នាំ២០២០ | ថ្នាក់ជាតិ | តម្រូវឲ្យ (Required) | បានលើកហើយ (Yes) | មិនទាន់ទេ (No) |
| ផ្សេងៗទៀត សូមបញ្ជាក់ដោយពណ៌នា (Others; specify in narrative) | មិនមានទេ (None) | មិនមានទេ (None) | - | - | - | - |



**បដិសេធការទទួលខុសត្រូវ:** របាយការណ៍នេះមានព័ត៌មាន និងទិន្នន័យដែលត្រឹមត្រូវល្អក្នុងកំឡុងពេលផ្សព្វផ្សាយប៉ុណ្ណោះ។ ដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩ ជាស្ថានការណ៍វិវឌ្ឍន៍ជាប្រចាំ ព័ត៌មាននៅក្នុងឯកសារនេះ អាចនឹងខុសទៅនឹងព័ត៌មានថ្មីៗ។